# កិច្ចសម្ភាសរបស់អ្នកមីង មាស ឆាយលីម

**កៈ អ្នកសម្ភាសឈ្មោះជង់ សីហា ខៈ អ្នកដែលត្រូវសម្ភាសឈ្មោះ មាស ឆាយលីម**

កៈ ចឹងជាមុនដំបូងខ្ញុំសូមអរគុណសម្រាប់ថ្ងៃនេះដែលអ៊ំបានចំណាយពេលវេលាក្នុងការសម្ភាសន៍ ទាក់ទងនឹងជីវប្រវត្តិផ្ទាល់ខ្លួនអ៊ំ និង បទពិសោធន៍មួយចំនួនចឹងណាអ៊ំ ហើយខ្ញុំដឹងថាកិច្ចការមួយនេះវាពិតជាមានផលប្រយោជន៍ និង ប្រទានពរជ័យសម្រាប់អ៊ំ និង ក្រុមគ្រួសារអ៊ំ ជាពិសេសគឺជាឪកាសមួយដ៏ល្អដែលអាចរក្សាទុកនៅឯកសារសម្រាប់កូនចៅរបស់អ៊ំនៅជំនាន់ទៀតចឹងណា។ បាទសូមជំរាបសួរអ៊ំសំរាប់ខ្ញុំឈ្មោះជង់ សីហា ជាអ្នកសម្ភាសន៍ដែលបានធ្វើឡើងនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៦។បាទហើយអញ្ចឹងខ្ញុំសូមសួរសំនួរបងឈ្មោះអីដែរ? ឈ្មោះពេញ?

ខៈ ឈ្មោះ មាស ឆាយលីម តែឈ្មោះខាងក្រៅហៅថា អាញ៉ូរ។

កៈ តើអ៊ំស្រីកើតនៅថ្ងៃខែឆ្នាំណាដែរ?

ខៈ កើតនៅឆ្នាំ១៩៥១ ។

កៈ ចុះបើគិតជាឆ្នាំខ្មែរវិញត្រូវនឹងសត្វអីគេដែរអ៊ំ? សត្វទាំង ១២ នោះអ៊ំ ?

ខៈ សត្វពោង បើឆ្នាំខ្មែរជាសត្វនាគ។

កៈ បាទអញ្ចឹង អ៊ំអាចជួយប្រាប់ពីទីកន្លែងកំណើតអ៊ំបានទេ?

ខៈ នៅស្រុកកោះសន្ធិន ខេត្តកំពង់ចាម។

កៈ អញ្ចឹងអ៊ំ ឥឡូវអ៊ំមានអាយុប៉ុន្មានដែរហើយអ៊ំ?

ខៈ ឥឡូវមានអាយុ ៦៦ ឆ្នាំហើយ។

កៈ អ៊ំអាចជួយប្រាប់ពីជីវប្រវត្តិនៃការរៀបអាពាហ៍ពិពាហ៍ តើអ៊ំប្រុសនិងអ៊ំស្រីបានជួយគ្នាដោយរបៀបណា ហើយអ៊ំពេលវេលានៅពេលរៀបអាពាហ៍ពិពាហ៍ទេ?

ខ៖ ដូចអ៊ំប្រុសបានប្រាប់ចឹង នៅឆ្នាំ ១៩៧១។

ក៖  ដោយសារតែនេះជាឯកសាររបស់អ៊ំផ្ទាល់តែម្តង ចឹងទោះបីជាទាក់ទងមួយអ៊ំប្រុសក៏ដោយ ក៏ខ្ញុំចង់សុំឲ្យអ៊ំឆ្លើយដែរណាអ៊ំ តើអ៊ំអាចជួយប្រាប់ពីពេលវេលានៃការជួបគ្នាដំបូងរវាងអ៊ំ និង អ៊ំប្រុសបានទ?

ខ៖ បានជួបគ្នាដំបូងនៅជំនាន់លន់នុល ពីមុនជំនាន់ប៉ុលពតតិច។

ក៖  ហើយអ៊ំអាចប្រាប់បានទេ ថាការរៀបអាពាហ៍ពិពាហ៍នោះបានរៀបចំដោយឪពុកម្តាយទាំងសងឬ ម៉េចដែរអ៊ំ?

ខ៖ ចាស ដោយឪពុកម្តាយទាំងសងខាង។

ក៖  ចុះរឿងបណ្ណាការនាសម័យនោះវិញយ៉ាងម៉េចទៅវិញដែរអ៊ំ?

ខ៖ មិនសូវច្រើនទេនាសម័យនោះ គ្រាន់តែបានរៀបការដោយឲ្យ ឪពុកម្តាយបានដឹងលឺតែប៉ុណ្ណឹងឯង។

ក៖  អញ្ចឹង តើមានចំណុចអ្វីខ្លះដែលធ្វើឲ្យអ៊ំស្រីសម្រេចចិត្តរៀបការជាមួយអ៊ំប្រុសទៅ?

ខ៖ ដោយសារតែគាត់មានចរិត មាយាទ រំទុំ សាកសម ក៏ចាប់អារម្មណ៍គាត់ ហើយក៏ព្រមទទូលយកគាត់ធ្វើជាស្វាមីទៅ។

ក៖  តើអ៊ំស្រី និង អ៊ំប្រុសស្គាល់គ្នាប៉ុន្មានឆ្នាំដែរពីមុខរៀបអាពាហ៍ពិពាហ៍?

ខ៖ ស្គាល់គ្នាប្រហែលជាជិតមួយឆ្នាំពីមុនរៀបការ។

ក៖  ខ្ញុំចង់សួរពីសមាជិកគ្រួសារអ៊ំវិញ តើអ៊ំមានបងប្អូនប៉ុន្មាននាក់ដែរអ៊ំ? ប្រុសប៉ុន្មាន ស្រីប៉ុន្មានដែរអ៊ំ?

ខ៖ មានបងប្អូន ៩នាក់ ប្រុស ៣ និងស្រី ៦ នាក់។

ក៖  ចឹងអ៊ំនៅចាំឈ្មោះពួកគាត់ទាំងអស់អត់ទេ?

ខ៖ បងស្រីរបស់ខ្ញុំឈ្មោះមាស ឆាយលី, បន្ទាប់ទៀតមាស ឆាយលៀម, មាស ថា, បន្ទាប់មកទៀត សុខុម(ប្រុស), មាស ឆាយនាង, បន្ទាប់មកទៀតគឺខ្ញុំ មាស ឆាយលីម ហើយប្អូនស្រីមាស ឡាងអៀង, មួយទៀតមាស ឡាងអេង, មាស ពេជ្យ។

ក៖  ចឹងតើអ៊ំជាកូនទីប៉ុន្មានដែរនៅក្នុងក្រុមគ្រួសារ?

ខ៖ (គាត់រៀបសិន) ខ្ញុំជាកូនទី ៥។

ក៖  អញ្ចឹងតើបងប្អូនទាំង ៩នាក់របស់អ៊ំពេលនេះពួកគាត់នៅឯណាដែរ?

ខ៖ ម្នាក់នៅជិតខ្ញុំ ហើយពីរនាក់ទៀតរស់នៅលើកោះ នៅតែរស់តែ ៣នាក់ទេ(គាត់រៀបឡើងវិញមួយប្តីគាត់) អូ! ខ្ញុំច្រឡំនៅរស់ ៥នាក់។

ក៖  តើអ៊ំស្រីនៅចាំឈ្មោះឪពុកម្តាយរបស់អ៊ំទេ?

ខ៖ ឪពុកឈ្មោះ មាស វ៉ាត និង ម្តាយឈ្មោះ ហោ ឡាវ

ក៖  បើគិតមកដល់ពេលនេះតើពួកគាត់មានអាយុប៉ុន្មានដែរហើយអ៊ំ?

ខ៖ អូ! មិនចាំទេ អាយុច្រើនហើយប្រហែលជា ១០០ឆ្នាំជាងទេដឹង, គាត់ប្រហែលជាស្លាប់នៅអាយុ១១០ ឬ ១២០។

ក៖  អញ្ចឹងតើអ៊ំអាចរៀបរាប់តិចៗខ្លះបានទេទាក់ទងពីប្រវត្តិរបស់ឪពុកម្តាយរបស់អ៊ំ? តើគាត់កើតឆ្នាំអី ឬ គាត់រស់នៅទីណាដែរ?

ខ៖: ខ្ញុំមិនចាំផង ដោយសារតែគាត់បានស្លាប់នៅពេលដែលខ្ញុំនៅតូចមានអាយុតែ ១២ឆ្នាំ ហើយគាត់ទើបតែមានអាយុ ៥០ឆ្នាំក៏ស្លាប់ទៅ។

ក៖  ចុះម្តាយរបស់អ៊ំវិញ?

ខ៖ គាត់ប្រហែលជាស្លាប់នៅអាយុ ៧០ ជាង គាត់ទើបតែស្លាប់នៅឆ្នាំ ១៩៩៧នេះទេ។

ក៖  តើអ៊ំអាចជួយប្រាប់បានទេពី បទពិសោធន៍អ្វីខ្លះដែលអ៊ំចាំ ដែលទាក់ទងនឹងឪពុកម្តាយអ៊ំនៅពេលដែលអ៊ំនៅក្មេងពេលដែលគាត់នៅរស់?

ខ៖ ខ្ញុំចាំខ្លះដែរ ប៉ារបស់ខ្ញុំគាត់បានកើតនៅពាម ចក, ឪពុកគាត់ តាកុងមាស ជាថៅកែឡោះ គាត់ទិញស្រូវ ដឹកជញ្ជូនស្រូវណឹងលក់ រួចទៅក្រោយមកទៀតគាត់ឈប់ធ្វើការណឹងទៅ ក៏ទៅធ្វើការជាមួយបារាំងវិញនៅឯថ្ម ពេជ្រយើងណឹង គាត់ធ្វើបានប៉ុន្មានឆ្នាំទេព្រោះគាត់មានជំងឺ ដោយសារតែគាត់ធ្លាក់ពីលើចុងឈើ ដោយសារជំងឺគាត់រាំរ៉ៃគាត់ក៏ស្លាប់នៅអាយុ ៥០ឆ្នាំទៅ។ ចឹងទៅខ្ញុំក៏កំព្រា អូយ បែកខ្ញាក់បងប្អូនអស់ហើយ ខ្ញុំទៅនៅជាមួយម្ដាយមីងខ្ញុំនៅឯថ្មពេជ្រនោះទៅ បងខ្ញុំគាត់ទៅនៅជាមួយឪពុកធំ អ៊ំខ្ញុំនៅឯស្ទួលនោះទៅ ហើយប្អូនខ្ញុំគាត់ទៅនៅជាមួយម្ដាយមីងនៅឯពោធិតុង ប្ដីគាត់សក្ដិប៉ុន្មានទេជាអ្នកបើកកប៉ាល់ហោះរ បែកខ្ញាក់គ្នាអស់ទៅ ឯប្អូនប្រុសខ្ញុំមួយនោះទៅរៀននាំជាមួយលោកតាំងពីតូចអាយុ ៧ឆ្នាំ បែកខ្ញាក់គ្នាអស់រលីង ក្រោយពេលដែលប៉ាខ្ញុំបានស្លាប់ទៅ ទៅនៅជាមួយលោកបានទិញខោអាវ ចិញ្ចឹម អាណិតប្អូនណាស់។ ហើយមកជំនាន់ក្រោយប៉ុល ពតណឹង បងខ្ញុំណឹងអាពតវាយកទៅសម្លាប់ចោល ប្អូនស្រីមួយទៀតតូចក្មេង កុមារណឹងប្អូនពៅ គេហៅកុមារៗទៅធ្វើការយកគ្នាទៅហើយស្លាប់បាត់ទៅមិនឃើញមកវិញទេ។

ក៖  ចុះអ៊ំចាំពីជីវប្រវត្តិរបស់ម្ដាយអ៊ំខ្លះទេ?

ខ៖ ម្ដាយខ្ញុំគាត់កំសត់ កំព្រា គាត់កំព្រាខាងម្ដាយវិញ ម្ដាយស្លាប់តាំងពីតូចហើយឪពុកគាត់ក៏យកប្រពន្ធក្រោយទៀត កូនក៏ច្រើនទៀត គាត់ក្រហើយលំបាកណាស់ ចេះតែចិញ្ចឹមកូនទៅ, មានតែបងខ្ញុំទៅដែលនៅបំរើម្ដាយខ្ញុំក្រៅពីណឹងបែកចោលគាត់អស់ ម្ដាយខ្ញុំគាត់កំសត់ណាស់។

ក៖  អ៊ំអាចជួយរៀបរាប់ពីជីវប្រវត្តិអ៊ំតាំងពីតូចមករហូតដល់ធំបានទេ?

ខ៖ កំសត់ណាស់មិនចង់និយាយទេ(គាត់បានសើច)

ក៖  អ៊ំអាចជួយរៀបរាប់តិចក៏បានដែរអ៊ំ?

ខ៖ ខ្ញុំទៅរៀនមិនបានខ្ពស់ទេបានត្រឹមថ្នាក់ទី ៣ទេ ពីដើមគេហៅថ្នាក់អាទិដ្ឋានបានត្រឹមថ្នាក់ទី ៣ ភូមិខ្ញុំណឹងមានត្រឹមថ្នាក់ទី ៣ទេ រួចទៅឆ្លងទៅកោះសន្ធិន រួចខ្ញុំគ្មានលទ្ធភាពរៀនទៀតទេ រៀនបានចប់តែថ្នាក់ណឹងក៏ឈប់រៀនទៅ។ បងបង្អស់របស់ខ្ញុំវិញរៀនតែនៅក្រោមផ្ទះគេទេ ហើយបងបន្ទាប់ៗគាត់រៀនបានខ្ពស់ៗជាងខ្ញុំ ហើយខ្ញុំរៀនមិនខ្ពស់រៀនបានតែប៉ុណ្ណឹង ចេះតែអាន ចេះតែមើលឲ្យចាំៗទៅ រួចខ្ញុំទៅជួយធ្វើថ្នាំ ស៊ីឈ្នួលគេណឹងណា ស៊ីឈ្នួលធ្វើថ្នាំឲ្យគេណឹងរាល់ឆ្នាំ បានតលុយមកចិញ្ចឹមគ្រួសារណឹងខ្លះ ប្អូននៅតូចៗណាស់ ពិបាកណាស់ ខ្ញុំកំស

ត់ណាស់ បានមកចូលជំនាន់ប៉ុល ពតណឹង គេហៅកងចល័តស្អីគេណឹងនោះ ពេលនោះខ្ញុំអាយុ ១៨ឆ្នាំ ថាឈឺនោះឈឺ ស្គមកដៃប៉ុនដងវែក ឈឺរាប់ឆ្នាំ ក្រោពេលឈឺហើយខ្ញុំក៏មានសាច់ឈាមធាត់ចឹងទៅ ការលំបាកវេទនាណាស់។

ខ៖ នៅពេលអ៊ំឈឺណឹងឈឺជំងឺអីដែរអ៊ំ?

ក៖  ជំងឺក្ដៅ ក្ដៅម៉ង វេីរវាយចឹងហើយបានខ្ញុំមិនសូវចងចាំ ហើយច្រើនដងណាស់ជំងឺណឹងមិនមែនតែម្ដងទេ ដល់មកកូនខ្ញុំអាទី ២ និយាយថាពីក្ដៅរវើរវាយអន្ទះសារម៉េងហើយវង្វេងបេះដូងញាក់កំរើកញ័រ ហើយញាក់ញរ័ទោះមនុស្សមកសង្កិតពីរបីរនាក់ក៏មិនឈ្នះដែរ ញាក់ៗមិនមែនរាប់ថ្ងៃទេ គឺរាប់ខែ ជិតមួយឆ្នាំ ជំនាន់ណឹងគេឲ្យដេកនៅពេទ្យ គេធ្វើថ្នាំសូន្យៗ ដែលគេហៅថាអាចម៍ទន្សាយ គេឲ្យលេបតែថ្នាំណឹង លេបៗរាប់ខែ ថាញាក់នោះញាក់ឲ្យរាល់តែថ្ងៃថ្ងៃណាក៏ញាក់ៗ ហូបអីមិនបានទេ ស្គមហើយខ្ញុំមិនមានទឹកដោះឲ្យកូនបៅ កូនស្រីមួយណឹងគាត់ស្លាប់ដោយសារចឹង ឈឺៗស្គមក្ដៅរវើរវាយ ហើយដោយសារតែយាយម៉បបានផ្សំថ្នាំឲ្យបានជា តែមកដល់កូនក្រោយអាកណ្ដាលនេះ ឈឺក្ដៅម្ដងទៀត គ្រួសារខ្ញុំគាត់បានទៅរកអាចារ្យ លែងដឹងខ្លួនហើយសន្លប់បាត់មាត់បាត់ករម៉ង ហើយភ្នែកខ្ញុំណឹងងងឹតមើលអីអត់ឃើញទេរាវរកកូន មើលអីអត់ឃើញសោះងងឹតឈឹងឈឺ ហើយពិបាកណាស់ខ្ញុំឈឺ ហើយចង់ដឹងពីជំនាន់ប៉ុល ពតនោះអី (អ្នកសម្ភាសន៍ឆ្លើយបាទអ៊ំ) ជំនាន់ប៉ុល ពតលំបាក ខ្ញុំមានផ្ទៃពោះគេប្រើច្រើនណាស់ គេប្រើទៅស្ទូង ទៅដក ហើយទៅណឹងមិនមែនផ្លូវស្រួលទេ ឆ្លងទឹកអូរប្រលាយហូរទៀត រួចទៅស្ទូងទឹកជ្រៅណាស់ ហើយមកវិញណឹងហូបតែបបរណឹង រួចឆ្លងទន្លេហើយបានតែប៉ុន្មានខែទេ ៣ខែទេគេប្រើទៀតហើយ គេប្រើឲ្យទៅច្រូត ហើយច្រូតណឹងគេដាក់កំណត់ម៉ែតឲ្យ ខំច្រូតឲ្យហើយឆាប់បានមកមើលកូន ដាក់កំណត់ ហើយពេលយើងច្រូតអស់ហើយណឹងគេថែមឲ្យទៀត គេពន្លើសម៉ែត្រឲ្យយើងទៀត បានវេទនាណាស់ រួចមកទៀតគេប្រើឲ្យទៅវែកដី វែកដីទប់ទំនប់ទន្លេ ពេលវែកដីទប់ទន្លេណឹងកូនខ្ចីទើបតែបានប៉ុន្មានខែណឹងហើយវែកនោះវែក ឈឺឡើងស្គមអស់ហើយកំសត់ណាស់ ចឹងហើយបានខួរក្បាលខ្ញុំមិនសូវចាំទេ ក្ដៅឡើងវង្វេងរួចបេះដូងខ្ញុំឥឡូវនេះវាឈឺ វាឈឺហើយចុកឆ្អឹងក្រោយដោយសារតែខ្ញុំក្ដៅញាក់ គ្រុនក្ដៅណឹង ចឹងហើយស្មារតីខ្ញុំមិនសូវចាំដូចនៅពីក្មេងទេ។

ក៖  ហើយខ្ញុំចង់ដឹងថានៅជំនាន់ណឹង អ៊ំកើតកូនបានប៉ុន្មាននាក់ដែរទៅអ៊ំ?

ខ៖ (គាត់រៀបហើយគាត់សិន) ៣នាក់ ហើយទំរាំតែរួច ធ្វើដំណើរដើររហូតដូចគ្រួសារខ្ញុំបាននិយាយចឹង ហើយធ្វើការគ្មានឈប់ឈរមិនដឹងថ្ងៃដឹងយប់ទេ(គាត់សើច) ដើររកស៊ីចិញ្ចឹមកូន

ក៖  ចឹងនៅជំនាន់ប៉ុល ពតណឹងអ៊ំបានផលវិបាកខ្លាំងទេក្នុងការថែទាំកូនអ៊ំ?

ខ៖ លំបាកណាស់ ហើយកូនៗណឹងយកទៅធ្វើរតែឃាយៗ វេទនាណាស់ពិបាកមែនទែនពួកខ្ញុំពោះធំយ៉ាងម៉េចក៏គេប្រើដែរអត់ឈប់ទេ ហើយឈឺតិចតួចៗអីអស់សំរាកទេ ទាល់តែឈឺនៅកន្ទេលដេកក្រោកលែងរួចនោះ ថាលំបាកៗខ្លាំងណាស់ ខ្ញុំមនុស្សស្រីផងថាលំបាកណាស់។

ក៖  ចុះអ៊ំខ្ញុំសុំស្គាល់ឈ្មោះកូន ៣នាក់ដែលបានកើតនៅជំនាន់ប៉ុល ពតបានទេ?

ខ៖ កូន ៣នាក់ណឹង , ប៉ាវ វណ្ណី, ប៉ាវ ស៊ីណាត, ប៉ាវ ណៃហ័រ។

ក៖  ចុះពេលបែកពីជំនាន់ណឹងកូនអ៊ំសរុបមានប៉ុន្មាននាក់ដែរ?

ខ៖ ទាំងអស់មកដលឥឡូវនេះមាន ៨នាក់ណឹងអស់ហើយ។

ក៖  អ៊ំអាចជួយរៀបរាប់ថែម ៥នាក់ទៀតបានទេអ៊ំ?

ខ៖ ប៉ាវ វណ្ណី, ប៉ាវ ស៊ីណាត, ប៉ាវ ណៃហ័រ, ប៊ុន ណា, តុលា, ធីតា, សុខា ហើយកក្កដា។

ក៖  ចឹងចង់សួរត្រលប់ទៅពីដំបូងវិញតិច ពេលដែលអ៊ំនៅក្មេងអ៊ំថាបានរៀនចប់ថ្នាក់ ៣ ហើយមែន?

ខ៖ ចាស បានត្រឹមថ្នាក់ទី ៣។

ក៖  អ៊ំនៅចាំពីកន្លែងដែលអ៊ំបានសិក្សាកាលនៅក្មេងទេ?

ខ៖ នៅឯសាលាកោះថ្មី រួចទៅខាងជូនម៉ៅឆ្លងទឹក កោះសន្ធិនឆ្លងទឹកទៀតចឹងអត់មានលទ្ធភាពរៀនបានខ្ពស់ទេ កំព្រាឪពុកពេលដែលប៉ាខ្ញុំស្លាប់ចោលតាំងពីក្មេង។

ក៖  អរគុណច្រើនអ៊ំ ហើយខ្ញុំចង់ចូលទៅកាន់សំណួរមួយទៀត តើអ៊ំអាចជួយចែកចាយពេលវេលាក្នុងជីវិតអ៊ំ ពេលវេលាណាដែលអ៊ំគិតថាវាលំបាកជាងគេ?

ខ៖ នៅពេលដែលមានផ្ទៃពោះឆ្លងទន្លេ ឈឺក្តៅណឹង វេទនាណាស់ វេទនាមែនទែន គ្រុនញាក់ឈឺណឹងគិតទៅធ្ងន់ៗ ៣ដងដល់មកពេលឥឡូវខ្ញុំនឹកឃើញគុណព្រះអង្គជួយបានរស់មកដល់ពេលនេះ បានស្គាល់ដំណឹងល្អ អរព្រះគុណព្រះអង្គខ្លាំងណាស់។

កៈ  តើអ្វីដែលអ៊ំចងចាំជាងគេក្នុងជីវិតរបស់អ៊ំ? អ្វីដែលល្អចឹងណាអ៊ំ? អ្វីដែលធ្វើឲ្យអ៊ំសប្បាយចិត្ត?

ខៈ ដោយសារកូនចៅរបស់អ៊ំណឹងណា គេមានសភាពសុភាពរាបសារមិនពិបាកប្រដៅ គេជាក្មេងសុភាពរាបសារណឹងហើយ ហើយជីវិតអ៊ំសប្បាយជាងគេគឺទទួលដំណឹងល្អណឹងហើយ ពិសេសម៉ងសប្បាយរីករាយមែនទែន ផុតទុក្ខកង្វល់អ្វីៗលែងខ្វល់ទាំងអស់ខាងលោកិយណឹង។

កៈ  ចឹងតាមបទពិសោធន៍អ៊ំ អ៊ំធ្លាប់ធ្វើការងារខាងចំការអត់អ៊ំ?

ខៈ ខាងចំការណឹង ទួល លី ហាលក្ដៅ ហើយថាចំការធ្វើថ្នាំ យប់ក្រោកគេសកថ្នាំ សកហាន់ហាលថ្ងៃ យ៉ាប់ណាស់ពេលសើម ចំការថ្នាំណឹងយ៉ាប់ជាងគេទាំងអស់ យ៉ាប់ណាស់ ហត់ណាស់ខ្ញុំនោះ(គាត់សើច) ។

កៈ  ចឹងបន្ទាប់ពីអ៊ំធ្វើការនៅចំការថ្នាំហើយ តើអ៊ំមានបទពិសោធន៍ធ្វើអ្វីផ្សេងទៀតទេ?

ខៈ (គាត់មិនបានឆ្លើយសំណួរទេ តែគាត់និយាយពី) កាលនៅសម័យនោះវារឹកវប្រជាជនគេចាប់យកធ្វើទាហាន កងនារីក្លាហានផ្សេងៗ។

កៈ  ចឹងមកដល់សំណួរចុងក្រោយ តើជីវិតអ៊ំសព្វថ្ងៃនេះ មានភាពខុសគ្នាអ្វីខ្លះកាលពីពេលដែលអ៊ំនៅក្មេង? អ៊ំអាចជួយបកស្រាយបានទេ?

ខៈ សព្វថ្ងៃខ្ញុំមានភាពរីករាយដូចថាផុតទុកកង្វល់ ខុសពីមុនមិនទាន់មានជំនឿ ខ្ញុំមានអំណរអរគុណដល់ព្រះអង្គណាស់បានធូរស្បើយជំងឺខ្ញុំអីណឹង ធូរស្បើយខ្លាំងមែនទេ ដូចថាព្រះអង្គបានជួយសម្រាលដល់ជំងឺណឹង ខ្ញុំធ្វើការបានរាល់ថ្ងៃមានអំណរណាស់ អរគុណព្រះអង្គអត់ភ្លេចគុណព្រះអង្គទេ។ចឹងអ៊ំធ្លាប់មានបទពិសោធន៍ទៅក្រៅប្រទេសទេអ៊ំ?

អ្នកឆ្លើយ: ដូចគ្រួសារខ្ញុំនិយាយចឹងទៅព្រះវិហារបរិសុទ្ធ?

កៈ  នៅប្រទេសណាដែរអ៊ំ?

ខៈ ទីក្រុងហុងកុង?

កៈ  អ៊ំធ្លាប់ទៅប៉ុន្មានដល់ដែរ?

ខ៖ យ: ទៅបានតែម្តងទេ។

ក៖  ហើយអ៊ំចាំទេ ថាឆ្នាំណាដែរ?

ខ៖ (គាត់គិតបន្តិច) ឆ្នាំ ២០០៩។

ក៖  នៅពេលអ៊ំទៅព្រះវិហារបរិសុទ្ធ តើអ៊ំមានអារម្មណ៍បែបណាដែរ?

ខ៖ មានអារម្មណ៏អរសប្បាយរីករាយណាស់ មិនដែលបានទេមួយជីវិតអ៊ំ ទើបតែស្គាល់ដំណឹងល្អរបស់ព្រះអង្គ ព្រះអង្គជួយប្រទានពរឲ្យបានទៅស្គាល់ប្រទេសគេ កុំអីអ៊ំនៅល្ងិតល្ងង់មិនយល់ថ្ងៃអាទិត្យ ថ្ងៃព្រហស្បត៏អីទេ គិតតែពីធ្វើការ ណឹងហើយមានអំណរនៅក្នុងចិត្តខ្ញុំសប្បាយណាស់ ទោះបីជាខ្ញុំក្រក៏ដួងចិត្តខ្ញុំមានអំណរសប្បាយរីករាយ។

ក៖  អរគុណច្រើនអ៊ំដែលអ៊ំបានផ្តល់ឪកាសក្នុងការសម្ភាសន៏មួយនេះ ហើយអ្វីជាចុងក្រោយគឺដោយសារតែពេលចុងបញ្ចប់មួយនេះ តើអ៊ំយល់ដើម្បីឲ្យពួកខ្ញុំដាក់សម្លេងណឹងនៅក្នុង Website របស់ BYU ទេអ៊ំ?

ខ៖ ខ្ញុំព្រម ខ្ញុំអរគុណណាស់ដែលបានមកជួយខ្ញុំ កុំអីខ្ញុំអត់ដឹងទៅបញ្ចូលតាមណាតាមណីទេ (គាត់សើច)។

ក៖ បាទចឹងខ្ញុំអរគុណអ៊ំច្រើនណាស់។